**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងបរិស្ថាន**
លេខ : ៩២៧ ស.ជ.ណ ប.ស្ក

## សេចក្តីជូនដំណឹង
## ស្តីពី ទិវាសំអាតពិភពលោក ( World Cleanup Day )

ក្រសួងបរិស្ថាន មានកិត្តិយសសូមជម្រាបជូនដំណឹងដល់សារព័ត៌មានជាតិ និងអន្តរជាតិ ជាពិសេសសាធារណជន ស្ថាប័នពាក់ព័ន្ធ រួមទាំងវិស័យឯកជនឱ្យបានជ្រាបថា ក្រសួងបរិស្ថាន សហការជាមួយក្រសួងអប់រំ យុវជននិងកីឡា ក្រសួងទេសចរណ៍ អង្គការ Let's Do It! និងអង្គការ GoGreen Cambodia នឹងប្រារព្ធទិវាសំអាតពិភពលោក (World Cleanup Day) ដោយផ្តោតសំខាន់លើការកាត់បន្ថយការបំពុលបរិស្ថាន និងការប្រើប្រាស់សំណល់ប្លាស្ទិក ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៨ វេលាម៉ោង ០៦:៣០នាទីព្រឹក ដល់ម៉ោង ១១:៣០នាទីព្រឹក នៅមុខទីស្តីការក្រសួងបរិស្ថាន រាជធានីភ្នំពេញ។ កម្មវិធីនេះធ្វើឡើងដើម្បីជំរុញនិងបំផុសឱ្យមានការចូលរួមពីសាធារណជននិងភាគីពាក់ព័ន្ធ ដែលជាចលនាសាកលដោយផ្សារភ្ជាប់មនុស្សនិងស្ថាប័ន ក្នុងគោលដៅធ្វើឱ្យពិភពលោកស្អាតគ្មានសំរាម។ ការអនុវត្តកម្មវិធីនេះ ជាការឆ្លើយតបនឹងបញ្ហាប្រឈមមួយចំនួនរបស់ប្រជាជនគ្រប់វិស័យ ដែលតម្រូវឱ្យមានការលើកទឹកចិត្តចូលរួមសកម្មភាពសំអាតបរិស្ថាន គ្រប់ទីកន្លែងនិងគ្រប់ពេលវេលា ដើម្បីឱ្យក្លាយជាចលនាសង្គមមួយពោរពេញទៅដោយភាពស្អាតទាំងនៅក្នុងប្រទេសកម្ពុជានិងលើពិភពលោក។

អាស្រ័យហេតុនេះ សូមអ្នកសារព័ត៌មានជាតិ និងអន្តរជាតិ ជាពិសេសសាធារណជន ក៏ដូចជាស្ថាប័នពាក់ព័ន្ធ វិស័យឯកជនជ្រាប និងចូលរួមក្នុងព្រឹត្តិការណ៍ខាងលើឱ្យបានច្រើនកុះករ។

ថ្ងៃ អង្គារ ២កើត ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ២០១៨

អគារមរតកតេជោ ដីឡូលេខ503 ផ្លូវកៅស៊ូរមមាត់ទន្លេបាសាក់ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ ទូរស័ព្ទ: ០២៣ ២១៣ ៩០៨, ០២៣ ២២០ ៣៦៩ ទូរសារ: ០២៣ ២១២ ៥៤០